# តើការតាមដានប្រវត្តិទំនាក់ទំនងមេរោគមានដំណើរការយ៉ាងដូចម្ដេច?

**ការតាមដានប្រវត្តិទំនាក់ទំនងមេរោគគឺជាដំណើរការសាមញ្ញ និងសម្ងាត់មួយដែលត្រូវបានប្រើប្រាស់ដោយមន្ទីរសុខាភិបាលសាធារណៈនានាជាច្រើនទសវត្សមកហើយ ដើម្បីបន្ថយល្បឿនការរីករាលដាលនៃជំងឺឆ្លង និងជៀសវាងការផ្ទុះឡើងនៃជំងឺផ្សេងៗ។ អ្នកអាចចូលរួមចំណែក ដោយឆ្លើយសំណួរសាមញ្ញមួយចំនួន។**

- ប្រសិនបើអ្នកទទួលបានការហៅទូរស័ព្ទពីមន្ត្រីសុខភាពសាធារណៈ នេះជាការចាំបាច់ក្នុងការទទួលទូរស័ព្ទនេះ។ វានឹងបង្ហាញនៅលើទូរស័ព្ទរបស់អ្នកជាអក្សរ “LA PublicHealth” ឬក៏មានលេខ 1-(833) 641-0305។
- ប្រសិនបើអ្នកទទួលបានសេចក្ដីបង្គាប់របស់មន្ត្រីសុខាភិបាលប្រចាំខោនធី Los Angeles ហើយមិនទាន់ទទួលបានការសម្ភាសន៍អំពីការតាមដានប្រវត្តិទំនាក់ទំនងមេរោគទេ អ្នកត្រូវតែទូរស័ព្ទទៅលេខនៅលើសេចក្ដីបង្គាប់នោះក្នុងចន្លោះពេល 24 ម៉ោង។
- អ្នកឯកទេសសុខភាពសាធារណៈអាចឆ្លើយសំណួររបស់អ្នក និងផ្ដល់ជូនអ្នកនូវព័ត៌មានដូចជារបៀបធ្វើតេស្តមេរោគ COVID-19 ការស្វែងរកគ្រូពេទ្យ ឬការរកជំនួយនៅខណៈពេលដែលអ្នកស្ថិតក្នុងការធ្វើចត្តាឡីស័ក ឬដាក់ខ្លួនឱ្យនៅដាច់ដោយឡែក។

## ប្រសិនបើលោក-អ្នកទទួលបានលទ្ធផលធ្វើតេស្តជំងឺ COVID-19 ជាវិជ្ជមាន៖



**បុគ្គលិកសុខភាពសាធារណៈនឹងសួរអំពី៖**

1. ទីកន្លែងដែលអ្នកបានទៅដល់។
2. មនុស្សដែលអ្នកនៅជិត នៅពេលអ្នកអាចចម្លងមេរោគបាន។

- ចំពោះជនដែលអ្នកបានប្រាប់ឈ្មោះទៅកាន់បុគ្គលិកសុខភាពសាធារណៈ ជននោះនឹងត្រូវទទួលបានការទាក់ទងទៅ ប៉ុន្តែឈ្មោះ និងព័ត៌មានទំនាក់ទំនងរបស់អ្នក ឬក៏ថាអ្នកមានផ្ទុកមេរោគ COVID-19 គឺមិនប្រាប់ទៅជននោះទេ។ ពួកគេនឹងមិនទទួលបានព័ត៌មានអ្វីអំពីអ្នកទេ គ្រាន់តែថាពួកគេត្រូវបានប៉ះពាល់ ឬមានទំនាក់ទំនងទៅនឹងជំងឺ COVID-19។

**ដើម្បីស្វែងយល់បន្ថែម សូមមើល** ***ការណែនាំនៃការនៅដាច់ដោយឡែក***

- សូមស្កេនកូដ QR ឬ
- ចូលទៅកាន់**ph.lacounty.gov/covidisolation**។

## ប្រសិនបើលោក-អ្នកបានប៉ះពាល់ ឬមានទំនាក់ទំនងជាមួយជនណាម្នាក់ដែលមានផ្ទុកមេរោគ COVID-19៖



**បុគ្គលិកសុខភាពសាធារណៈនឹងសួរអំពី៖**

1. ថាតើលោក-អ្នកមានរោគសញ្ញាជំងឺ COVID-19 ឬក៏លោក-អ្នកបានធ្វើតេស្តរួចរាល់ឬនៅ។
2. ទីកន្លែងដែលអ្នកបានទៅដល់។

- ដើម្បីជៀសវាងការភាន់ច្រឡំរវាងព័ត៌មានរបស់អ្នក និងអ្នកដទៃ សូមផ្ដល់ព័ត៌មានរបស់អ្នកឱ្យបានពេញលេញ និងត្រឹមត្រូវ។
- បុគ្គលិកសុខភាពសាធារណៈអាចទូរស័ព្ទទៅកាន់អ្នកច្រើនជាងមួយដង ដើម្បីពិនិត្យតាមដានសុខភាពរបស់អ្នក។
- ពួកគេនឹងផ្ដល់ជូនអ្នកនូវព័ត៌មានអំពីជំហានជាបន្តបន្ទាប់ ដោយផ្អែកលើចម្លើយរបស់អ្នក។

**ដើម្បីស្វែងយល់បន្ថែម សូមមើល** ***ការណែនាំអំពីការធ្វើចត្តាឡីស័កនិងការណែនាំផ្សេងៗសម្រាប់អ្នកមានទំនាក់ទំនងជិតស្និទ្ធ***

- សូមស្កេនកូដ QR ឬ
- ចូលទៅកាន់**ph.lacounty.gov/covidquarantine**។